01146405

E367

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 21 / 09 / 2015
ម៉ោង (Time/Heure) : 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ៖ | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម **Claudia FENZ** |
| | ចៅក្រម យុរ ឧត្តរា |
| កាលបរិច្ឆេទ៖ | ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ៖ | សម្ងាត់ សាធារណៈ |

# សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកជំនាញដែលមានឈ្មោះសម្ងាត់ 2-TCE-95

**សហព្រះរាជអាជ្ញា**

ជា លាង
Nicolas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

**ជនជាប់ចោទ**

នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ**

សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាស្នើឱ្យកោះហៅបុគ្គលដែលមានរហស្សនាម 2-TCE-95 មកផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ ទាក់ទងនឹងប្រធានបទដែលត្រូវជំនុំជម្រះពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិចាមក្នុងសំណុំរឿង ០០២/០២[1]។ មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងការជ្រើសរើសបុគ្គលដែលមានរហស្សនាម 2-TCE-95 ធ្វើជាអ្នកជំនាញ។ នៅក្នុងអំឡុងពេលសវនាការបឋមបន្ថែមដែលបានធ្វើឡើងនៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញភាគីឱ្យផ្តល់មតិយោបល់ទៅលើការជំទាស់នានាដែលមេធាវីការពារក្តី ខៀវ សំផន[2] បានលើកឡើង។

## ២. សារណា

២. សហព្រះរាជអាជ្ញាស្នើថា បុគ្គលដែលមានរហស្សនាម 2-TCE-95 គួរត្រូវបានសួរដេញដោលនៅចំពោះមុខអង្គជំនុំជម្រះទៅលើប្រធានបទនានាដូចខាងក្រោម៖

> ការគាបសង្កត់ផ្នែកសាសនាទៅលើជនជាតិចាម ដោយពួកខ្មែរក្រហមចាប់ពីឆ្នាំ ១៩៧០ ការបះបោររបស់ជនជាតិចាមនៅឆ្នាំ ១៩៧៥ ការសម្លាប់ពួកអ្នកបះបោរជនជាតិចាមទាំងប្រុសទាំងស្រី ការជម្លៀសដោយបង្ខំចំពោះជនជាតិចាម ការសម្លាប់ជនជាតិចាមនៅស្រុកក្រូចឆ្មារនៅឆ្នាំ ១៩៧៨ ការសម្លាប់អ្នកទោសជាជនជាតិចាមនៅមន្ទីរសន្តិសុខ ស-២១ និងការប៉ាន់ស្មានពីចំនួនជនជាតិចាមដែលត្រូវបានសម្លាប់ដោយសារគោលនយោបាយរបស់ខ្មែរក្រហម[3]។

៣. ក្នុងការគាំទ្រគុណវុឌ្ឍិរបស់បុគ្គលដែលមានរហស្សនាម 2-TCE-95 ជាអ្នកជំនាញ សហព្រះរាជ-អាជ្ញាបានលើកឡើងអំពីបទសម្ភាសន៍នានា ដែលបានធ្វើឡើងដោយបុគ្គលដែលមានរហស្សនាម 2-TCE-95 ជាមួយនឹងជនរងគ្រោះ និងសាក្សី នៅក្នុងដំណើរការរៀបចំសៀវភៅចំនួនពីរដែលគាត់

---

[1] ឧបសម្ព័ន្ធ ៣៖ សេចក្តីសង្ខេបអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់ ក.ស.ព ដែលបានធ្វើបច្ចុប្បន្នភាព ឯកសារ E305/6.4 ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៤៧ ដល់ ៤៨។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ២៖ បញ្ជីឈ្មោះអ្នកជំនាញរបស់ ក.ស.ព ឯកសារ E9/4.2 ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ទំព័រ ៨។

[2] ប្រតិចារឹកសវនាការ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ (សវនាការបឋមបន្ថែម) ទំព័រ ៥៣។

[3] ឧបសម្ព័ន្ធ ៣៖ សេចក្តីសង្ខេបអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់ ក.ស.ព ដែលបានធ្វើបច្ចុប្បន្នភាព ឯកសារ E305/6.4 ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៤៧ ដល់ ៤៨។

បាននិពន្ធស្តីពីការប្រព្រឹត្តិចំពោះជនជាតិចាមនៅក្នុងអំឡុងរបបខ្មែរក្រហម។ សហព្រះរាជអាជ្ញាក៏បានបញ្ជាក់ថា បុគ្គលដែលមានរហស្សនាម 2-TCE-95 ធ្លាប់ជាអ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ហើយបច្ចុប្បន្ន គាត់បម្រើការងារជាអ្នកវិភាគនៅការិយាល័យសហចៅក្រមស៊ើបអង្កេត អ.វ.ត.ក (ក.ស.ច.ស)[4]។

៤. មេធាវីការពារក្តី ខៀវ សំផន បានឆ្លើយតបថា សហព្រះរាជអាជ្ញាមិនបានផ្តល់ព័ត៌មានអំពីកម្រិតសញ្ញាប័ត្រ ឬទីកន្លែងសិក្សារបស់បុគ្គលដែលមានរហស្សនាម 2-TCE-95 បានទទួល និងការសិក្សាឡើយ[5]។ មេធាវីការពារក្តីក៏បានលើកឡើងអំពីការព្រួយបារម្ភទៅលើភាពមិនលម្អៀងរបស់បុគ្គលដែលមានរហស្សនាម 2-TCE-95 ដោយពិចារណាទៅលើការងាររបស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា វិធីសាស្ត្រនៃការបង្ហាញការពិតអំពីប្រវត្តិសាស្ត្រ ចោទជាបញ្ហា និងការងារបច្ចុប្បន្នរបស់គាត់ជាមួយ ក.ស.ច.ស ផងដែរ[6]។ ចុងក្រោយ មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងការជ្រើសរើសបុគ្គលដែលមានរហស្សនាម 2-TCE-95 ធ្វើជាអ្នកជំនាញ ដោយសារតែឋានៈរបស់គាត់ជាជនរងគ្រោះ និងជាសាក្សីនៅក្នុងព្រឹត្តិការណ៍មួយចំនួន ដែលមិនសមស្របទៅនឹងគុណវុឌ្ឍិរបស់គាត់ជាអ្នកជំនាញឡើយ[7]។

៥. សហព្រះរាជអាជ្ញាបានឆ្លើយតបថា ការស្រាវជ្រាវដែលនាំឱ្យមានការបោះពុម្ពផ្សាយសៀវភៅចំនួនពីរដែលនិពន្ធដោយបុគ្គលដែលមានរហស្សនាម 2-TCE-95 ដែលត្រូវបានបញ្ចូលនៅក្នុងបញ្ជីឯកសារសំណុំរឿង ០០២/០២ "ផ្តល់ការបង្ហាញគ្រប់គ្រាន់ថា ... [2-TCE-95] គឺជាអ្នកជំនាញមានគុណវុឌ្ឍិក្នុងការផ្តល់សក្ខីកម្មអំពីបញ្ហានេះបាន"[8]។ សហព្រះរាជអាជ្ញាក៏លើកឡើងផងដែរថា

---

[4] ឧបសម្ព័ន្ធ ៣៖ សេចក្តីសង្ខេបអំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់ ក.ស.ព ដែលបានធ្វើបច្ចុប្បន្នភាព ឯកសារ E305/6.4 ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៤៧។

[5] *សេចក្តីជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ចំពោះការកោះហៅបុគ្គលមួយចំនួនដែលស្នើមកផ្តល់សក្ខីកម្មសម្រាប់សំណុំរឿង ០០២/០២ និងសំណើសុំការបំភ្លឺលើវិសាលភាពជាក់លាក់នៃការពិភាក្សាវេញដោល បន្ទាប់ពីសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង E301/9/1* ឯកសារ E305/9 ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ (សេចក្តីជំទាស់របស់ ខៀវ សំផន) កថាខណ្ឌ ៤១, ៤២។

[6] សេចក្តីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ៤១ ដល់ ៤២។ *សូមមើលផងដែរ* ប្រតិចារិកសវនាការ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ (សវនាការបឋមបន្ថែម) ទំព័រ ៧៩។

[7] សេចក្តីជំទាស់របស់ ខៀវ សំផន កថាខណ្ឌ ៤២។

[8] ប្រតិចារិកសវនាការ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ (សវនាការបឋមបន្ថែម) ទំព័រ ៥៤។

បញ្ហាទាក់ទងទៅនឹងភាពមិនលម្អៀងគឺជាបញ្ហាដែលពាក់ព័ន្ធទៅនឹងទម្ងន់នៃភស្តុតាង ជាជាងភាពអាចទទួលយកបាននៃភស្តុតាង[9]។

## ៣. ច្បាប់ជាធរមាន

៦. វិធាន ៣១ នៃវិធានផ្ទៃក្នុងចែងថា អង្គជំនុំជម្រះអាចស្វែងរកជំនួយជាមតិយោបល់ពីអ្នកជំនាញ "អំពីបញ្ហាដែលយល់ឃើញថាមានសារៈសំខាន់ចាំបាច់ដល់ [...] កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក" (វិធាន ៣១(១) នៃវិធានផ្ទៃក្នុង និងត្រូវចាត់តាំងអ្នកជំនាញតាមដីកាសម្រេចដែលចែងច្បាស់អំពីភារកិច្ច និងថេរវេលាបំពេញការងាររបស់អ្នកជំនាញ (វិធាន ៣១(៣) នៃវិធានផ្ទៃក្នុង))។ អនុលោមតាមវិធាន ៨០*ស្ទួន*(២) នៃវិធានផ្ទៃក្នុង៖ "នៅពេលអង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថាការស្តាប់ [...] អ្នកជំនាញដែលត្រូវបានស្នើសុំនឹងមិននាំមកនូវដំណើរការល្អនៃការស្វែងរកយុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងត្រូវបដិសេធសំណើសុំឱ្យកោះហៅបុគ្គលនោះ"។ វិធានផ្ទៃក្នុងមិនបានផ្តល់និយមន័យនៃអ្នកជំនាញ ឬកំណត់អំពីគុណវុឌ្ឍិអប្បបរមា ឬបទពិសោធន៍ដែលបុគ្គលម្នាក់ត្រូវមាន ដើម្បីទទួលបានការតែងតាំងជាអ្នកជំនាញនៅ អ.វ.ត.ក នោះទេ។

៧. អនុលោមតាមយុត្តិសាស្ត្រអន្តរជាតិ អ្នកជំនាញគឺជាបុគ្គលដែលមានចំណេះដឹងជំនាញ បទពិសោធន៍ ឬជំនាញដែលអាចជួយដល់អង្គជំនុំជម្រះក្នុងការយល់ដឹងទៅលើបញ្ហាវិវាទជាក់លាក់ដែលតម្រូវឱ្យមានចំណេះដឹងពិសេសលើវិស័យមួយជាក់លាក់[10]។ អ្នកជំនាញផ្តល់នូវការបំភ្លឺ បរិបទ ឬជំនួយបន្ថែម ក្នុងគោលបំណងដើម្បីឱ្យអង្គជំនុំជម្រះអាចវាយតម្លៃទៅលើភស្តុតាងបាន[11]។ អង្គជំនុំជម្រះបានរកឃើញថា ក្នុងករណីដែលអ្នកជំនាញអាចមានចំណេះដឹងផ្ទាល់ខ្លួនលើ

---

[9] ប្រតិចារឹកសវនាការ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៤ (សវនាការបឋមបន្ថែម) ទំព័រ ៥៤។

[10] សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ ឯកសារ E215 ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២ (សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ) កថាខណ្ឌ ១៦។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Popovic និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-88-T សេចក្តីសម្រេចលើការជូនដំណឹងតាមវិធាន ៩៤ ស្ទួនរបស់មេធាវីការពារក្តី ទាក់ទិននឹងសាក្សីជំនាញរបស់រដ្ឋអាជ្ញា Richard Butler ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ (សេចក្តីសម្រេចលើ Richard Butler នៅតុលាការ ICTY) កថាខណ្ឌ ២៣។ *រឿងក្តី Nahimana តទល់នឹង រដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-99-52-A សាលដីកា ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ (សាលដីកាលើបណ្តឹងសាទុក្ខក្នុង*រឿងក្តី Nahimana*) កថាខណ្ឌ ១៩៨។

[11] សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ កថាខណ្ឌ ១៦។

អង្គហេតុនានាពាក់ព័ន្ធនឹងរបបកម្ពុជាប្រជាធិបតេយ្យ បន្ថែមទៅនឹងឋានៈជាអ្នកជំនាញនោះ គាត់អាចនឹងត្រូវចោទសួរអំពីអង្គហេតុទាំងនោះដែរ[12]។

៨. អង្គជំនុំជម្រះសាលាដំបូងគឺជាអ្នកសម្រេចថាតើ បុគ្គលណាម្នាក់អាចនឹងត្រូវកោះហៅឱ្យមកផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញ ឬយ៉ាងណា។ បញ្ហានៅចំពោះមុខអង្គជំនុំជម្រះគឺថាតើ អ្នកជំនាញដែលបានស្នើឡើង មានជំនាញ ឬចំណេះដឹងពាក់ព័ន្ធ ដែលអាចជួយដល់អង្គជំនុំជម្រះ ដែលជាអ្នកស្វែងរកការពិត ឱ្យយល់អំពីភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ដែរឬយ៉ាងណា[13]។ ក្នុងការសម្រេចថាតើអ្នកជំនាញដែលបានស្នើឡើង មានជំនាញ ឬចំណេះដឹងពាក់ព័ន្ធដែរ ឬយ៉ាងណានោះ អង្គជំនុំជម្រះសាលាដំបូងអាចពិចារណាទៅលើប្រវត្តិរូបការងាររបស់បុគ្គលនោះ អត្ថបទនិពន្ធ ការបោះពុម្ពផ្សាយ ឬព័ត៌មានផ្សេងៗទៀត រួមទាំង តួនាទីពីមុន និងបច្ចុប្បន្នរបស់អ្នកជំនាញដែលបានស្នើឡើងនោះ[14]។ លើសពីនេះទៀត ការដែលអ្នកជំនាញដែលបានស្នើឡើងធ្លាប់មានទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅ ឬបច្ចុប្បន្ន កំពុងបំពេញការងារជាមួយការិយាល័យមួយនៅ អ.វ.ត.ក មិនធ្វើឱ្យគាត់គ្មានគុណវុឌ្ឍិក្នុងការកោះហៅឱ្យមកផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញនោះទេ[15]។

---

[12] សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ កថាខណ្ឌ ១៨។ សេចក្តីសម្រេចស្តីពីការជ្រើសរើសអ្នកជំនាញដែលមានរហស្សនាម TCE-33 ឯកសារ E283 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ (សេចក្តីសម្រេចស្តីពីការជ្រើសរើសអ្នកជំនាញដែលមានរហស្សនាម TCE-33) កថាខណ្ឌ ១៦។

[13] *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង សេចក្តីសម្រេចលើសំណើសុំវិធានការការពារសាក្សី និងអ្នកជំនាញ និង លើសំណើរបស់ភាគីសុំស្តាប់ចម្លើយសាក្សី និងអ្នកជំនាញ មូលហេតុ ឯកសារ E40/1 ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩ កថាខណ្ឌ ២៦។ *សូមមើលផងដែរ* សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ កថាខណ្ឌ ១៦។

[14] សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ កថាខណ្ឌ ១៦។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Zdravko Tolimir* សំណុំរឿងលេខ IT-05-88/2-T សេចក្តីសម្រេចលើការទទួលយករបាយការណ៍អ្នកជំនាញ Ratko Skrbic ជាមួយនឹងមតិយោបល់ដោយឡែករបស់ចៅក្រម Mindua និងមតិយោបល់ជំទាស់របស់ចៅក្រម Nyambe ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ១៤។ សេចក្តីសម្រេចលើ Richard Butler នៅតុលាការ ICTY កថាខណ្ឌ ២៤។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Vojislaw Seselj* សំណុំរឿងលេខ IT-03-67-T សេចក្តីសម្រេចលើឋានៈរបស់អ្នកជំនាញ Reynaud Theunens, ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ (សេចក្តីសម្រេច Reynaud Theunens នៅតុលាការ ICTY កថាខណ្ឌ ២៨)។

[15] សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ កថាខណ្ឌ ១៥។ សេចក្តីសម្រេចស្តីពីការជ្រើសរើសអ្នកជំនាញដែលមានរហស្សនាម TCE-33 កថាខណ្ឌ ១៣។ *រឿងក្តី កាំង ហ្គេកអ៊ាវ ហៅ ឌុច* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង សេចក្តីសម្រេចលើសំណើសុំវិធានការការពារសាក្សី និងអ្នកជំនាញ និង លើសំណើរបស់ភាគីសុំស្តាប់ចម្លើយសាក្សី និង

៩. ការជំទាស់ពាក់ព័ន្ធនឹងភាពលម្អៀង ឬខ្វះឯករាជ្យភាពរបស់បុគ្គលដែលត្រូវបានកោះហៅជាអ្នកជំនាញ គឺជាបញ្ហាដែលជាប់ពាក់ព័ន្ធទៅនឹងទម្ងន់នៃភស្តុតាងដែលគាត់ផ្តល់ឲ្យ ជាជាងភាពអាចទទួលយកបាននៃភស្តុតាង[16]។ លើសពីនេះទៀត កម្រិតនៃភាពពាក់ព័ន្ធរបស់អ្នកជំនាញដែលបានស្នើឡើងនៅក្នុងការស៊ើបអង្កេត ឬការរៀបចំនៃការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ឬផលប៉ះពាល់នៃចំណេះដឹងផ្ទាល់ខ្លួនជាសាក្សី ឬការឈឺចាប់ដែលគាត់បានទទួលរងក្នុងនាមជាជនរងគ្រោះនៃព្រឹត្តិការណ៍នានាដែលជាប់ពាក់ព័ន្ធនឹងជំនាញ គឺជាបញ្ហាដែលអាចស្វែងយល់បានក្នុងពេលសួរដេញដោល ហេតុដូច្នេះ វាផ្តល់ឱកាសពេញលេញដល់ជនជាប់ចោទក្នុងការជំទាស់ទៅនឹងភស្តុតាងរបស់អ្នកជំនាញ[17]។ ការវាយតម្លៃពីគុណវុឌ្ឍិ និងភាពលម្អៀងរបស់អ្នកជំនាញដែលបានស្នើឡើង ត្រូវធ្វើឡើងទៅតាមករណីជាក់ស្តែង ដោយពិចារណាលើកាលៈទេសៈទាំងអស់[18]។

## ៤. <u>ការវិភាគ</u>

១០. អង្គជំនុំជម្រះរម្លឹកឡើងវិញថា ភស្តុតាងនៃគុណវុឌ្ឍិនៃការសិក្សាស្រាវជ្រាវ មិនមែនជាលក្ខខណ្ឌសម្រាប់ឲ្យបុគ្គលណាម្នាក់មានគុណវុឌ្ឍិជាអ្នកជំនាញនោះទេ។ ដូចបានកត់សម្គាល់ខាងលើ អង្គ-ជំនុំជម្រះសាលាដំបូងអាចពិចារណាទៅលើប្រវត្តិរូបការងាររបស់បុគ្គលនោះ អត្ថបទនិពន្ធ ការបោះពុម្ពផ្សាយ ឬព័ត៌មានផ្សេងៗទៀត រួមទាំង តួនាទីពីមុន និងបច្ចុប្បន្នរបស់អ្នកជំនាញដែលបាន

---

អ្នកជំនាញ សង្ខេប ឯកសារ E40 ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៩ ទំព័រ ៥។ សេចក្តីសម្រេច Reynaud Theunens នៅតុលាការ ICTY កថាខណ្ឌ ២៩។

[16] សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ កថាខណ្ឌ ១៥។ សេចក្តីសម្រេចស្តីពីការជ្រើសរើសអ្នកជំនាញដែលមានរហស្សនាម TCE-33 កថាខណ្ឌ ១៣។ *សូមមើលផងដែរ* សេចក្តីសម្រេចលើ Richard Butler នៅតុលាការ ICTY កថាខណ្ឌ ២៦។ សេចក្តីសម្រេចលើ Reynaud Theunens នៅតុលាការ ICTY កថាខណ្ឌ ២៨ ដល់ ២៩។

[17] *សូមមើល* សេចក្តីសម្រេចស្តីពីការជ្រើសរើសអ្នកជំនាញដែលមានរហស្សនាម TCE-33 កថាខណ្ឌ ១៣ ដល់ ១៥។ សាលដីកាលើបណ្តឹងសាទុក្ខក្នុង*រឿងក្តី Nahimana* កថាខណ្ឌ ១៩៩។ សេចក្តីសម្រេចលើ Richard Butler នៅតុលាការ ICTY កថាខណ្ឌ ២៨-២៩។

[18] សេចក្តីសម្រេចស្តីពីការជ្រើសរើសអ្នកជំនាញដែលមានរហស្សនាម TCE-33 កថាខណ្ឌ ១៤ និង ការដកស្រង់នៅក្នុងឯកសារនោះ។ នៅទីនេះ អង្គជំនុំជម្រះបានកត់សម្គាល់ថា នៅក្នុងករណីទាំងពីរនៅចំពោះមុខតុលាការ ICTY បុគ្គលដដែលនេះត្រូវបានបដិសេធឋានៈជាអ្នកជំនាញ ដោយសារភាពពាក់ព័ន្ធរបស់គាត់ទៅក្នុងការស៊ើបអង្កេត ដែលថា មតិយោបល់របស់គាត់មិនអាចត្រូវបានចាត់ទុកថាមានភាពមិនលម្អៀងទេ ដែលអាចនាំឲ្យមានសេចក្តីសន្និដ្ឋានសំខាន់ ចំពោះពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទ។ ទោះជាយ៉ាងណា បុគ្គលដដែលនេះត្រូវបានកោះអញ្ជើញមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីនៅចំពោះមុខតុលាការ ICTY។

ស្មើឡើង ដើម្បីសម្រេចថាតើ អង្គជំនុំជម្រះនឹងស្ដាប់សក្ខីកម្មរបស់គាត់ក្នុងឋានៈជាអ្នកជំនាញ ដែរ ឬយ៉ាងណា[19]។ អង្គជំនុំជម្រះកត់សម្គាល់ថា បុគ្គលដែលមានរហស្សនាម 2-TCE-95 បានបំពេញការងារជាច្រើនឆ្នាំក្នុងនាមជាអ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាស្ថាប័នជំនាញក្នុងការរៀបចំបញ្ជី និងធ្វើការវិភាគទៅលើសម្ភារៈឯកសារស្ដីពីរបបខ្មែរក្រហម ក្នុងគោលបំណងប្រវត្តិសាស្ត្រ ហើយបច្ចុប្បន្នគាត់បំពេញការងារជាអ្នកវិភាគនៅ ក.ស.ច.ស។ ក្នុងពេលគាត់បំពេញការងារជាអ្នកស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា បុគ្គលដែលមានរហស្សនាម 2-TCE-95 បាននិពន្ធសៀវភៅចំនួនពីរ ដោយផ្អែកលើការស្រាវជ្រាវរបស់គាត់ទៅលើប្រវត្តិសាស្ត្ររបស់ជនជាតិចាមនៅក្នុងអំឡុងរបបខ្មែរក្រហម ដែលសៀវភៅទាំងពីរនោះមាននៅក្នុងសំណុំរឿង និងត្រូវបានយកមកសំអាងនៅក្នុងដីកាដំណោះស្រាយ[20]។ សៀវភៅមួយក្នុងចំណោមសៀវភៅទាំងពីរនេះ ក៏បានបង្ហាញពីវិធីសាស្ត្រស្រាវជ្រាវរបស់បុគ្គលដែលមានរហស្សនាម 2-TCE-95 យកមកប្រើដើម្បីរៀបចំសៀវភៅនោះដែរ[21]។ អង្គជំនុំជម្រះកត់សម្គាល់ថា បុគ្គលដែលមានរហស្សនាម 2-TCE-95 បានធ្វើការស្រាវជ្រាវយ៉ាងលម្អិត និងបានធ្វើបទសម្ភាសន៍ជាច្រើនជាមួយជនរងគ្រោះ និងសាក្សី នៅក្នុងដំណើរការរៀបចំសៀវភៅទាំងនេះ[22]។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា សម្រង់អត្ថបទមួយចំនួនពីក្នុងសៀវភៅទាំងពីរនេះត្រូវបានភាគីជាច្រើនយកមកប្រើប្រាស់នៅក្នុងតុលាការរួចហើយ ដោយរួមទាំងក្រុមមេធាវីការពារក្ដីទាំងពីរក្រុមដែរ[23]។ សៀវភៅមួយក្នុងចំណោមសៀវភៅទាំងពីរនេះផ្ដល់នូវរឿងរ៉ាវជាច្រើនរបស់សាក្សីដែលបានឃើញផ្ទាល់ភ្នែកចំពោះព្រឹត្តិការណ៍នានាដែលបានកើតមានឡើងនៅស្រុកក្រូចឆ្មារ ពីឆ្នាំ ១៩៧០

---

[19] *សូមមើល ខាងលើ* កថាខណ្ឌ ៨។

[20] ឧបសម្ព័ន្ធ ៣៖ សេចក្ដីសង្ខេបអំពីសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់ ក.ស.ព ដែលបានធ្វើបច្ចុប្បន្នភាព ឯកសារ E305/6.4 ចុះថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៤ ទំព័រ ៤៧។ អ៊ីសា អូស្មាន (Ysa Osman) *អ៊ុកអ៊ូបា (Oukoubah)៖ យុត្តិធម៌សំរាប់ចាមមូស្លីមនៅក្រោមរបបកម្ពុជាប្រជាធិតេយ្យ* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ២០០២) ឯកសារ E3/1822។ អ៊ីសា អូស្មាន (Ysa Osman) *ការបះបោររបស់ចាម៖ រឿងរ៉ាវរបស់អ្នកនៅរស់ក្នុងភូមិ* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ២០០៦) ឯកសារ E3/2653។ *សូមមើល* ដីកាដំណោះស្រាយ កថាខណ្ឌ ៧៥៨ ដល់ ៧៨៩។

[21] អ៊ីសា អូស្មាន (Ysa Osman) *អ៊ុកអ៊ូបា (Oukoubah)៖ យុត្តិធម៌សំរាប់ចាមមូស្លីមនៅក្រោមរបបកម្ពុជាប្រជាធិតេយ្យ* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ២០០២) ឯកសារ E3/1822 ទំព័រ v ១៤៩ ដល់ ១៥១។

[22] អ៊ីសា អូស្មាន (Ysa Osman) *អ៊ុកអ៊ូបា (Oukoubah)៖ យុត្តិធម៌សំរាប់ចាមមូស្លីមនៅក្រោមរបបកម្ពុជាប្រជាធិតេយ្យ* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ២០០២) ឯកសារ E3/1822 ទំព័រ ១០១ ដល់ ១១៨, ១៤៩ ដល់ ១៥១។

[23] សូមមើល ប្រតិចារិកសវនាការ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៥ (អ៊ិត សែន) ទំព័រ ៧០-៧២,៨៣-៨៤។ ប្រតិចារិកសវនាការ ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៥ (ស៊ុះ មីន) ទំព័រ ១០-១១, ២១,៣៤,៣៦-៣៨,៤១,៤៤,៤៦-៤៧។

ដល់ឆ្នាំ ១៩៧៩ ដែលបុគ្គលដែលមានរហស្សនាម 2-TCE-95 ប្រមូលបានក្នុងរយៈពេលបីឆ្នាំ។ ផ្អែកលើរឿងរ៉ាវទាំងនេះ និងសម្ភារៈឯកសារ បុគ្គលរូបនេះបានផ្តល់ការវិភាគពីគោលនយោបាយរបស់ខ្មែរក្រហមចំពោះជនជាតិចាម និងពីរបៀបដែលគោលនយោបាយនេះត្រូវបានយកទៅអនុវត្តពីឆ្នាំ ១៩៧០ រហូតដល់ឆ្នាំ ១៩៧៩[24]។ សៀវភៅនេះក៏បានលើកឡើងអំពីការបះបោរពីរលើករបស់ជនជាតិចាម ប្រឆាំងនឹងខ្មែរក្រហមនៅខែ កញ្ញា និងខែ តុលា ឆ្នាំ ១៩៧៥ ដែលត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ[25]។ សៀវភៅមួយទៀតដែលនិពន្ធដោយបុគ្គលដែលមានរហស្សនាម 2-TCE-95 ពិពណ៌នាពីជនជាតិចាមចំនួន ១៣ នាក់ដែលត្រូវបានឃុំឃាំងនៅមន្ទីរ ស-២១។ គាត់បានប្រៀបធៀបទិន្នន័យស្តីពីការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់ពួកគេម្នាក់ៗ ពីឯកសារនៅមន្ទីរ ស-២១ ជាមួយនឹងព័ត៌មានដែលសមាជិកគ្រួសាររបស់ពួកគេបានផ្តល់ឱ្យ និងសាក្សីផ្សេងទៀតដែលអ្នកនិពន្ធបានសម្ភាស...។ បន្ទាប់មក នៅក្នុងសៀវភៅនោះ គាត់បានវិភាគពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យចំពោះសាសនាអ៊ីស្លាម ដោយផ្អែកលើប្រវត្តិរូបមនុស្សទាំង ១៣ នាក់នោះ រួមទាំងឯកសារផ្សេងៗទៀត[26]។ អង្គជំនុំជម្រះយល់ឃើញថា ចំណេះដឹងពិសេសដែលបុគ្គលរូបនេះទទួលបាន តាមរយៈការងារ និងការស្រាវជ្រាវដែលគាត់បានធ្វើដើម្បីរៀបចំសៀវភៅទាំងពីរនេះ អាចជួយដល់អង្គជំនុំជម្រះក្នុងការយល់ដឹងពីភស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះ ពាក់ព័ន្ធនឹងប្រធានបទស្តីពីការប្រព្រឹត្តិចំពោះជនជាតិចាម។

១១. ទាក់ទងនឹងការព្រួយបារម្ភពីភាពលម្អៀងរបស់បុគ្គលដែលមានរហស្សនាម 2-TCE-95 អង្គជំនុំជម្រះរម្លឹកឡើងវិញថា ការជំទាស់ទៅនឹងភាពលម្អៀង និងមិនឯករាជ្យរបស់អ្នកជំនាញ គឺជាបញ្ហាដែលពាក់ព័ន្ធនឹងការវាយតម្លៃភស្តុតាង មិនពាក់ព័ន្ធដល់ភាពអាចទទួលយកបាននៃភស្តុតាងនោះទេ[27] ហើយសន្និដ្ឋានថា ភាគីនឹងអាចពិនិត្យទៅលើភាពលម្អៀង និងមិនឯករាជ្យរបស់អ្នកជំនាញបាន នៅក្នុងអំឡុងពេលដែលគាត់មកផ្តល់សក្ខីកម្ម។ ចំណុចនេះនឹងជួយដល់អង្គជំនុំជម្រះបន្ថែមទៀតក្នុងការផ្តល់ទម្ងន់ដល់សក្ខីកម្មរបស់អ្នកជំនាញ 2-TCE-95 ឱ្យបានសមស្រប រួមទាំង

---

[24] អ៊ីសា អូស្មាន (Ysa Osman) *ការបះបោររបស់ចាម៖ រឿងរ៉ាវរបស់អ្នកនៅរស់ក្នុងភូមិ* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ២០០៦) ឯកសារ E3/2653។

[25] អ៊ីសា អូស្មាន (Ysa Osman) *ការបះបោររបស់ចាម៖ រឿងរ៉ាវរបស់អ្នកនៅរស់ក្នុងភូមិ* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ២០០៦) ឯកសារ E3/2653 ទំព័រ ៥៣ ដល់ ១១២។ ដីកាដំណោះស្រាយ កថាខណ្ឌ ៧៥៨ ដល់ ៧៥៩។

[26] អ៊ីសា អូស្មាន (Ysa Osman) *អ៊ុកអ៊ូបា (Oukoubah)៖ យុត្តិធម៌សំរាប់ចាមមូស្លីមនៅក្រោមរបបកម្ពុជាប្រជាធិតេយ្យ* (ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ២០០២) ឯកសារ E3/1822 ទំព័រ ១១ ដល់ ៧៥, ៧៧ ដល់ ១០០។

[27] *សូមមើល ខាងលើ* កថាខណ្ឌ ៨ ដល់ ៩។

ឯកសារទាំងឡាយដែលមាននៅក្នុងកំណត់ហេតុដែលគាត់បាននិពន្ធ។ លើសពីនេះទៀត អង្គជំនុំជម្រះរម្លឹកឡើងវិញថា ភ័ស្តុតាង ឬសេចក្តីសន្និដ្ឋានដែលបានធ្វើឡើងដោយអ្នកជំនាញ មិនចងកាតព្វកិច្ចចំពោះអង្គជំនុំជម្រះនោះទេ ហើយថា ភ័ស្តុតាង និងសេចក្តីសន្និដ្ឋានទាំងនេះ នឹងស្ថិតនៅក្រោមបញ្ញត្តិនៃវិធាន និងការត្រួតពិនិត្យដូចគ្នាទៅនឹងភ័ស្តុតាងផ្សេងៗទៀតដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះផងដែរ។

១២. ចុងក្រោយ អង្គជំនុំជម្រះយល់ឃើញថា ឋានៈជាជនរងគ្រោះ និងជាសាក្សីអង្គហេតុនៃរបបខ្មែរក្រហមរបស់អ្នកជំនាញរូបនេះ មិនមានលក្ខណៈគ្រប់គ្រាន់ដែលត្រូវដកគាត់ចេញពីការផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញនោះទេ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះនឹងពិចារណាទៅលើឋានៈរបស់គាត់ជាជនរងគ្រោះ និងជាសាក្សីអង្គហេតុ នៅពេលវាយតម្លៃពីភ័ស្តុតាងរបស់គាត់។ អនុលោមតាមការអនុវត្តន៍របស់អង្គជំនុំជម្រះនេះ ដោយពិចារណាឃើញថា បុគ្គលដែលមានរហស្សនាម 2-TCE-95 អាចមកផ្តល់សក្ខីកម្មលើបញ្ហាអង្គហេតុបាន អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់គាត់ទៅលើអង្គហេតុពាក់ព័ន្ធនានា[28]។

១៣. យោងតាមចំណុចទាំងអស់ខាងលើ អង្គជំនុំជម្រះយល់ឃើញថា ជាប្រយោជន៍យុត្តិធម៌ដែលត្រូវកោះហៅបុគ្គលដែលមានរហស្សនាម 2-TCE-95 មកផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញ។

---

[28] *សូមមើល* សេចក្តីសម្រេចលើការចាត់តាំងអ្នកជំនាញ កថាខណ្ឌ ១៨។ សេចក្តីសម្រេចស្តីពីការជ្រើសរើសអ្នកជំនាញដែលមានរហស្សនាម TCE-33 កថាខណ្ឌ ១៦។

E 367

## ផ្អែកទៅលើសំអាងហេតុនានាដែលបានលើកឡើង អង្គជំនុំជម្រះសាលាដំបូង៖

**ច្រានចោល** ការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន។

**បញ្ជាក់** ថា អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់បុគ្គលដែលមានរហស្សនាម 2-TCE-95 ក្នុងឋានៈជាអ្នកជំនាញ។

**សម្រេច** ថា អ្នកជំនាញដែលមានរហស្សនាម 2-TCE-95 អាចត្រូវបានសួរដេញដោលទៅលើបញ្ហាទាំងអស់ដែលជាចំណេះដឹង ឬជំនាញរបស់គាត់ ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិចាម ក្នុងសំណុំរឿង ០០២/០២។ និង

**ណែនាំ** សហព្រះរាជអាជ្ញាឲ្យចាប់ផ្តើមក្នុងការតាំងសំណួរទៅអ្នកជំនាញដែលមានរហស្សនាម 2-TCE-95 មុនភាគីផ្សេងទៀត អនុលោមតាមវិធាន ៩១ និង ៩១*ស្ទួន* នៃវិធានផ្ទៃក្នុង។

ភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៥
ប្រធានអង្គជំនុំជម្រះសាលាដំបូង

TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE DE PREMIERE INSTANCE

**និល ណុន**